# « តើអ្នករាល់គ្នាគួរធ្វើជាមនុស្សបែបណាទៅ ? »

អែលឌើរ លីន ជី រ៉ូប៊ីន
នៃពួកចិតសិបនាក់

*សូមឲ្យការខិតខំរបស់អ្នកក្នុងការអភិវឌ្ឍលក្ខណៈដូចព្រះគ្រីស្ទបានទទួលជោគជ័យ ដើម្បីឲ្យរូបភាពរបស់ទ្រង់មាននៅលើទឹកមុខរបស់អ្នក និងសូមឲ្យលក្ខណៈរបស់ទ្រង់សម្តែងចេញតាមការប្រព្រឹត្តរបស់អ្នក ។*

« ដូច្នោះ ឬមិនដូច្នោះ ? » ( Hamlet វគ្គទី 3 ឈុតទី 1 ) គឺជាសំណួរដ៏ល្អណាស់ ។ ព្រះអង្គសង្គ្រោះបានសួរសំណួរនៅក្នុងរបៀបមួយដែលជ្រាលជ្រៅជាងនោះទៅទៀត ដែលធ្វើឲ្យវាជាសំណួរនៃគោលលទ្ធិដ៏សំខាន់មួយ សម្រាប់យើងម្នាក់ៗ ៖ « តើអ្នករាល់គ្នាគួរ *ធ្វើជា* មនុស្សបែបណាទៅ ? យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា ត្រូវឲ្យបានដូច *ជាយើង* » ( នីហ្វៃទី 3 27:27 )។ ទ្រង់បានអញ្ជើញយើងឲ្យយកព្រះនាមរបស់ទ្រង់ និងលក្ខណៈរបស់ទ្រង់ដាក់លើខ្លួនយើង ។

ដើម្បីក្លាយដូច *ជា* ទ្រង់ យើងត្រូវតែ *ធ្វើ* អ្វីៗដែលទ្រង់ *បានធ្វើ* ផងដែរ ៖ « ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា នេះហើយជាដំណឹងល្អរបស់យើង ហើយអ្នករាល់គ្នាស្គាល់ការណ៍ទាំងឡាយ ដែលអ្នករាល់គ្នាត្រូវ *ធ្វើ* នៅក្នុងសាសនាចក្ររបស់យើង ត្បិតកិច្ចការទាំងឡាយដែលអ្នករាល់គ្នាបានឃើញយើង *ធ្វើ* យ៉ាងណា នោះអ្នករាល់គ្នាត្រូវ *ធ្វើ* យ៉ាងនោះដែរ » ( នីហ្វៃទី 3 27:21 ) ។

*ការប្រែក្លាយ* និង *ទង្វើ* គឺមិនអាចបំបែកចេញពីគ្នាបានទេ ។ នៅពេលវាជាគោលលទ្ធិឯករាជ វាពង្រឹង និងគាំទ្រគ្នាទៅវិញទៅមក ។ ឧទាហរណ៍ សេចក្តីជំនឿបំផុសមនុស្សម្នាក់ឲ្យអធិស្ឋាន ហើយការអធិស្ឋានពង្រឹងជំនឿរបស់មនុស្សម្នាក់ ។

ជាញឹកញាប់ ព្រះអង្គសង្គ្រោះបានស្តីបន្ទោសពួកអ្នកដែល « ធ្វើ » តែគ្មាន « ការប្រែក្លាយ » — ដោយហៅពួកគេជា ពួកអ្នកមានពុត ៖ « ជនជាតិនេះគេគោរពប្រតិបត្តិអញតែបបូរមាត់ទេ ឯចិត្តគេនៅឆ្ងាយពីអញណាស់ » ( ម៉ាកុស 7:6 ) ។ *ទង្វើ* តែគ្មាន *ការប្រែក្លាយ* គឺជាការលាក់ពុត ឬក្លែងជាអ្វីដែលគេមិនមែនជា —នោះគឺជាអ្នកធ្វើពុត ។

ផ្ទុយទៅវិញ *ការប្រែក្លាយ* តែគ្មាន *ទង្វើ* ក៏គ្មានតម្លៃដែរ ដូចក្នុងគម្ពីរចែងថា « ឯសេចក្តីជំនឿក៏បែបដូច្នោះដែរ បើគ្មានការប្រព្រឹត្តតាមទេ នោះក៏ស្លាប់នៅតែឯង » ( យ៉ាកុប 2:17 ) ។ *ការប្រែក្លាយ* តែគ្មាន *ទង្វើ* គឺមិនមែនជា *ការប្រែក្លាយ* ដ៏ពិតប្រាកដនោះទេ វាជាការបំភាន់ ដែលជឿថាមនុស្សម្នាក់ជាមនុស្សល្អគ្រាន់តែដោយសារចេតនារបស់ម្នាក់នោះល្អ ។

*ទង្វើ* តែគ្មាន *ការប្រែក្លាយ* ( ការមានពុត ) បង្ហាញរូបភាពក្លែងក្លាយ ទៅកាន់អ្នកដទៃទៀត ខណៈដែល *ការប្រែក្លាយ* តែគ្មាន *ទង្វើ* បង្ហាញពីរូបភាពក្លែងក្លាយទៅកាន់អ្នកនោះខ្លួនឯងផ្ទាល់ ។

ព្រះអង្គសង្គ្រោះបានស្តីបន្ទោសដល់ពួកអាចារ្យ និងពួកផារិស៊ី ចំពោះការលាក់ពុតរបស់គេថា ៖ « វេទនាដល់អ្នករាល់គ្នា ពួកអាចារ្យ និងពួកផារិស៊ី ជាមនុស្សកំពុតអើយ ត្បិតអ្នករាល់គ្នាថ្វាយ 1 ភាគក្នុង 10 » នេះជាអ្វីដែលពួកគេ *បានធ្វើ* « ទាំងជីរអង្កាម ជីរលីងល័ក្ត និងល្ងផង តែបានចោល *សេចក្តី*សំខាន់ជាង ដែលនៅក្នុងក្រឹត្យវិន័យវិញ ដូចជាសេចក្តីយុត្តិធម៌ សេចក្តីមេត្តាករុណា និងសេចក្តីជំនឿ » ( ម៉ាថាយ 23:23 ) ។ ពួកគេមិនបាន *ប្រែក្លាយ* ជាអ្វីដែលពួកគេគួរតែ *ប្រែក្លាយ* នោះទេ ។

នៅពេលដែលទ្រង់បានទទួលស្គាល់ពីសារៈសំខាន់នៃ *ទង្វើ* នោះព្រះអង្គសង្គ្រោះក៏បានចង្អុលបង្ហាញពី *ការប្រែក្លាយ* ថាជា « សេចក្តីសំខាន់ជាង » ។ សារៈសំខាន់នៃ *ការប្រែក្លាយ* ត្រូវបានបង្ហាញនៅក្នុងឧទាហរណ៍ដូចតទៅនេះ ៖

- ការចូលទៅក្នុងទឹកនៃបុណ្យជ្រមុជទឹកគឺជា *ទង្វើ* ។ ‹ *ការប្រែក្លាយ* › ដែលត្រូវតែកើតឡើងមុននោះ គឺជំនឿលើព្រះយេស៊ូវគ្រីស្ទ និងការផ្លាស់ប្តូរដ៏អស្ចារ្យនៅក្នុងដួងចិត្ត ។

• ការទទួលទានសាក្រាម៉ង់គឺជា *ទង្វើ* ។ *ការប្រែក្លាយ* ជាសក្តិសមដើម្បីទទួលទានសាក្រាម៉ង់ជាសេចក្តីសំខាន់ជាង ។

• ការតែងតាំងបព្វជិតភាពជាអំពើ ឬ *ទង្វើ* ។ សេចក្តីសំខាន់ជាង គឺអំណាចដែលនៅក្នុងបព្វជិតភាព ដែលផ្អែកលើ « គោលការណ៍នៃសេចក្តីសុចរិតប៉ុណ្ណោះ » ឬជា *ការប្រែក្លាយ* ។ ( គោលលទ្ធិ និងសេចក្តីសញ្ញា 121:36 ) ។

ពួកយើងជាច្រើនបង្កើតតារាងដែលត្រូវ *ធ្វើ* ដើម្បីរំលឹកយើងពីអ្វីដែលយើងចង់សម្រេចឲ្យបាន ។ ប៉ុន្តែមនុស្សកម្រធ្វើតារាងនៃ *ការប្រែក្លាយ* ណាស់ ។ ហេតុអ្វី ? ការ *ធ្វើ* គឺជាសកម្មភាព ឬព្រឹត្តិការណ៍ទាំងឡាយ ហើយយើងអាចគូសធិកនៅពេលយើង *ធ្វើរួចប់* ។ *ការប្រែក្លាយជា* គឺមិនដែលចប់ទេ ។ អ្នកមិនអាចទទួលគំនូសធិកជាមួយនឹងតារាងនៃ *ការប្រែក្លាយ* បានទេ ។ ខ្ញុំអាចយកភរិយារបស់ខ្ញុំទៅក្រៅដើម្បីមានពេលវេលាដ៏ល្អមួយនៅល្ងាចថ្ងៃសុក្រនេះ នេះជា *ទង្វើ* ។ ប៉ុន្តែដើម្បី *ប្រែក្លាយ* ជាស្វាមីដ៏ល្អ មិនមែនជាព្រឹត្តិការណ៍ទេ វាត្រូវតែជាផ្នែកនៃធម្មជាតិរបស់ខ្ញុំ ចរិតរបស់ខ្ញុំ ឬជាខ្ញុំតែម្តង ។

ឬជាឪពុកម្នាក់ តើនៅពេលណា ដែលខ្ញុំអាចគូសធិកកូនម្នាក់ពីតារាងរបស់ខ្ញុំថា *បានធ្វើចប់ហើយ* ? យើងមិនដែលធ្វើចប់នូវ *ការប្រែក្លាយ* ជាឪពុកម្តាយដ៏ល្អនោះទេ ។ ហើយក្នុងការធ្វើជាឪពុកម្តាយដ៏ល្អ រឿងដ៏សំខាន់បំផុតមួយដែលយើងអាចបង្រៀនកូនៗរបស់យើងគឺ របៀបដើម្បី *ប្រែក្លាយដូចជា* ព្រះអង្គសង្គ្រោះ ។

ការមានលក្ខណៈដូច *ជា* ព្រះគ្រីស្ទ មិនអាចមើលឃើញនោះទេ ប៉ុន្តែលក្ខណៈទាំងនោះជាកម្លាំងជំរុញពីខាងក្រោយអ្វីដែលយើង *ធ្វើ* ដែលជាអ្វីដែលអាចមើលឃើញ ។ ឧទាហរណ៍នៅពេលដែលឪពុកឬម្តាយម្នាក់ជួយកូនឲ្យរៀនដើរ យើងឃើញ *ទង្វើ* របស់គាត់ ដូចជាទប់កូនឲ្យនឹង និងសរសើរកូនរបស់គាត់ ។ *ទង្វើ* ទាំងនេះបង្ហាញពីសេចក្តីស្រឡាញ់ដែលយើងមើលមិនឃើញនៅក្នុងដួងចិត្តរបស់ពួកគាត់ និងសេចក្តីជំនឿ និងសេចក្តីសង្ឃឹមដែលយើងមើលមិនឃើញ ដែលពួកគាត់មានសក្តានុពលរបស់កូនគាត់ ។ ពីមួយថ្ងៃទៅមួយថ្ងៃ ការខិតខំរបស់ពួកគាត់ចេះតែបន្ត —ដែលជាភស្តុតាងនៃ *ការប្រែក្លាយ* ដែលយើងមើលមិនឃើញ នៃភាពអត់ធ្មត់ និងភាពឧស្សាហ៍ព្យាយាម ។ ពីព្រោះ *ការប្រែក្លាយ* បង្កើត *ទង្វើ* និងជាអ្វីដែលជំរុញពីក្រោយ *ទង្វើ* នោះការបង្រៀនអំពី *ការប្រែក្លាយ* នឹងធ្វើអោយការប្រព្រឹត្តមានប្រសិទ្ធភាព ជាជាងការផ្តោតទៅលើ *ទង្វើ* ។

នៅពេលដែលក្មេងៗមានចរិតមិនល្អ ឧទាហរណ៍ នៅពេលពួកគេឈ្លោះគ្នា ជាញឹកញាប់យើងដាក់វិន័យខុសចំពោះអ្វីដែលពួកគេ *បានធ្វើ* ឬការឈ្លោះប្រកែកដែលយើងបានសង្កេត ។ ប៉ុន្តែ *ទង្វើ*—ដែលជាការប្រព្រឹត្តិរបស់ពួកគេ គឺគ្រាន់តែជាសញ្ញានៃការជំរុញដែលមើលមិនឃើញដែលនៅក្នុងដួងចិត្តរបស់គេប៉ុណ្ណោះ ។ យើងប្រហែលជាសួរខ្លួនឯងថា « បើសិនជាក្មេងម្នាក់បានយល់ តើអ្វីខ្លះដែលនឹងកែប្រែនូវការប្រព្រឹត្តិនេះនៅក្នុងពេលអនាគត ? អត់ធ្មត់ និងអភ័យទោស នៅពេលដែលមានគេរំខាន ? ស្រឡាញ់ និងធ្វើជាអ្នកសម្របសម្រួល ? ទទួលខុសត្រូវសម្រាប់ទង្វើរបស់មនុស្សម្នាក់ ហើយមិនស្តីបន្ទោស ? »

តើឪពុកម្តាយបង្រៀនកូនៗពីលក្ខណៈទាំងនេះដោយរបៀបណា ? ឱកាសល្អបំផុត ដើម្បីបង្រៀន និងបង្ហាញលក្ខណៈដូចព្រះគ្រីស្ទ ទៅកាន់កូនៗរបស់យើង គឺនៅក្នុងរបៀបដែលយើងហាត់ពត់លត់ដំពួកគេនោះឯង ។ ការហាត់ពត់លត់ដំមានឫសគល់ពីសិស្ស ហើយផ្នែករបស់យើងគឺតម្រូវឲ្យមានការអត់ធ្មត់ និងការបង្រៀន ។ វាមិនគប្បីធ្វើឡើងដោយកំហឹងនោះទេ ។ យើងអាច និងគប្បីប្រដៅតាមរបៀបដែលគោលលទ្ធិ និងសេចក្តីសញ្ញា កណ្ឌទី 121 បង្រៀនយើង « លើកលែងតែដោយការលួងលោម ដោយការអត់ធ្មត់ ដោយការទន់ភ្លន់ និងការស្លូតបូត និងដោយការស្រឡាញ់ស្មោះត្រង់ប៉ុណ្ណោះ ដោយចិត្តល្អ និងការចេះដឹងពេញទី » ។ ទាំងនេះ គឺជា*ការប្រែក្លាយ* ដូចជាព្រះគ្រីស្ទ ដែលគប្បីជាផ្នែកនៃអត្តសញ្ញាណរបស់យើងដែលជាឪពុកម្តាយ និងជាសិស្សរបស់ព្រះគ្រីស្ទ ។ ( ខ 41-42 )

តាមរយៈការហាត់ពត់លុតដំ នោះកូនម្នាក់អាចរៀនពីលទ្ធផលទាំងឡាយ ។ នៅក្នុងគ្រាបែបនោះ វាជាប្រយោជន៍ក្នុងការបង្វែរភាពអវិជ្ជមាន ទៅជាភាពវិជ្ជមានវិញ ។ ប្រសិនបើ កូនសារភាពកំហុស សូមសរសើរចំពោះសេចក្តីក្លាហានដែលជំរុញគេឲ្យសារភាព ។ ចូរសួរកូនពីអ្វីដែលគេបានរៀនពីកំហុស ឬពីសេចក្តីអាក្រក់ដែលមានចំពោះគេ ហើយសំខាន់ជាងនោះទៅទៀត ពីអ្វីដែលផ្តល់ឱកាសដល់ព្រះវិញ្ញាណឲ្យប៉ះ និងបង្រៀនពួកគេ ។ នៅពេលយើងបង្រៀនពួកគេដោយព្រះវិញ្ញាណពីគោលលទ្ធិ នោះគោលលទ្ធិនោះមាននូវអំណាចដើម្បីផ្លាស់ប្តូរធម្មជាតិពួកគេ ( *ការប្រែក្លាយ* ) ។

អាលម៉ា បានស្គាល់ពីគោលលទ្ធិដដែលនេះដែលថា « ការផ្សាយព្រះបន្ទូល មានបណ្ដាការដ៏ធំក្នុងការដឹកនាំប្រជាជន ឲ្យធ្វើនូវអ្វីៗដែលត្រឹមត្រូវ — មែនហើយ វាមានប្រសិទ្ធភាពទៅលើគំនិតមនុស្សច្រើនជាងផ្លែដាវ... » ហេតុអ្វី ? ព្រោះផ្លែដាវផ្ដោតតែទៅលើការប្រព្រឹត្តិនៃការដាក់ទោស ( *ទង្វើ* ) ប៉ុណ្ណោះ ខណ:ដែលការផ្សាយព្រះបន្ទូលបានផ្លាស់ប្ដូរធម្មជាតិមនុស្ស ដែលពួកគេ *បានប្រែក្លាយ* ឬអាច *ប្រែក្លាយ* ។ ( អាលម៉ា 31:5 )

កូនដ៏ស្ដាប់បង្គាប់ម្នាក់នឹងចុះឈ្មោះឪពុក ឬម្ដាយរបស់គេ នៅក្នុង*ថ្នាក់ហ្វឹកហ្វឺនឪពុកម្ដាយកម្រិត 101* ( កម្រិតទាប ) ប៉ុណ្ណោះ ។ ប្រសិនបើអ្នកត្រូវបានប្រទានពរជាមួយនឹងកូនម្នាក់ដែលសាកល្បងការអត់ធ្មត់របស់អ្នក រហូតដល់កម្រិត នោះអ្នកត្រូវចុះឈ្មោះក្នុង *ថ្នាក់ហ្វឹកហ្វឺនឪពុកម្ដាយកម្រិត 505* ( កម្រិតខ្ពស់ ) ។ ជំនួសឲ្យការឆ្ងល់ ថាអ្នកបានធ្វើអ្វីខុស នៅក្នុងជីវិតមុនផែនដីនេះ បានជាអ្នកទទួលរឿងបែបនេះ នោះអ្នកអាចគិតថាកូនដ៏លំបាកម្នាក់ គឺជាពរជ័យ និងឱកាសដើម្បីឲ្យអ្នកក្លាយដូចជាព្រះ ។ តើកូនណាមួយ ដែលនឹងធ្វើឲ្យការអត់ធ្មត់ និងការអត់ធន់ និងលក្ខណ:ដូចព្រះគ្រីស្ទផ្សេងទៀត ត្រូវបានសាកល្បងជាង អភិវឌ្ឍជាង និងដុសខាត់ជាង ? តើអាចទៅជាអញ្ចឹងទេ ថាអ្នកត្រូវការកូនរបៀបនេះ ខ្លាំងដូចជាកូននេះត្រូវការអ្នកដែរ ?

យើងទាំងអស់គ្នាបានឮដំបូន្មានដែលកាត់ទោសដល់អំពើបាប មិនមែនអ្នកធ្វើអំពើបាបទេ ។ ដូចគ្នាដែរ នៅពេលដែលកូនៗរបស់យើងមានចរិតមិនល្អ យើងត្រូវតែប្រុងប្រយ័ត្ន កុំនិយាយអ្វីដែលធ្វើឲ្យពួកគេជឿថា អ្វីដែលគេ *បានធ្វើ* គឺជាអ្វីដែលពួកគេ *ប្រែក្លាយ* ។ « កុំអនុញ្ញាតឲ្យការបរាជ័យវិវឌ្ឍពីសកម្មភាពមួយ ទៅជាអត្តសញ្ញាណមួយ ដែលមានស្លាកសញ្ញាដូចជា ‹ ភ្លីភ្លើ › — ‹ យឺតយ៉ាវ › — ‹ ខ្ជិលច្រអូស › ឬ ‹ ឆ្គាំឆ្គង › »[1] ។ កូនៗរបស់យើងគឺជាកូនចៅរបស់ព្រះ ។ នោះជាអត្តសញ្ញាណ និងសក្ដានុពលដ៏ពិតរបស់ពួកគេ ។ ផែនការដ៏ពិតរបស់ទ្រង់ គឺដើម្បីជួយកូនចៅរបស់ទ្រង់យកឈ្នះលើ កំហុស និងអំពើអាក្រក់ទាំងឡាយ និងដើម្បីរីកចម្រើនឡើង ឲ្យ*ក្លាយដូចជា* ទ្រង់ ។ ហេតុដូច្នោះហើយ ការប្រព្រឹត្តិមិនល្អ គួរតែត្រូវបានចាត់ទុកថាជាអ្វីមួយបណ្ដោះអាសន្ន — មិនមែនអចិន្ត្រៃយ៍នោះទេ វាជាអំពើ មិនមែនជាអត្តសញ្ញាណនោះទេ ។

ការភាន់ច្រឡំពីអត្តសញ្ញាណ ក៏អាចកើតឡើងផងដែរ ពេលយើងសួរកូនម្នាក់ពីអ្វីដែលគេចង់ *ប្រែក្លាយ* ពេលគេធំឡើង ដូចជាអ្វីដែលមនុស្សម្នាក់ *ធ្វើ* សម្រាប់ចិញ្ចឹមជីវិត គឺជាអ្វីដែលគេ *ប្រែក្លាយ* ។ មិនមែនជាវិជ្ជាជីវ: ហើយក៏មិនមែនជាមុខរបរដែរ ដែលកំណត់ពីអត្តសញ្ញាណ ឬតម្លៃផ្ទាល់ខ្លួននោះ ។ ព្រះអង្គសង្គ្រោះគឺជាជាងឈើដ៏រាបសា ប៉ុន្តែជាងឈើនោះស្ទើរតែមិនអាចបង្ហាញពីជីវិតរបស់ទ្រង់ ។

ក្នុងការជួយកូនម្នាក់រកឃើញថាអ្វីដែលគេប្រែក្លាយ និងពង្រឹងនូវតម្លៃផ្ទាល់ខ្លួនគេ យើងអាចលើកសរសើរដោយត្រឹមត្រូវចំពោះអ្វីដែលគេសម្រេចបាន ឬការប្រព្រឹត្ត — *ទង្វើ* — ប៉ុន្តែវាប្រសើរជាងនោះទៅទៀត ដើម្បីផ្ដោតការសរសើរជាចម្បងរបស់យើង ចំពោះលក្ខណ: និងជំនឿរបស់ពួកគេ — ជាអ្វីដែលពួកគេ *ប្រែក្លាយ* ។

នៅក្នុងការប្រកួតកីឡាមួយ របៀបដ៏ឆ្លាតវៃនៅក្នុងការសរសើរដល់ការប្រកួត ( ទង្វើ ) របស់កូនៗយើង គឺតាមរយ:ទស្សន:នៃ *ការប្រែក្លាយ* ដូចជាកម្លាំងការតស៊ូព្យាយាម ការមិនតក់ស្លុតចំពោះគូរប្រកួត ជាដើម ។ ដូចជាអ្វីដែលលើកឡើង គឺសរសើរទាំងអ្វីដែលជា *ការប្រែក្លាយ* និង *ទង្វើ* ។

នៅពេលយើងសុំឲ្យកូនៗ *ធ្វើ* កិច្ចការផ្សេងៗ យើងអាចរកមើលផងដែរពីរបៀបសរសើរពួកគេទៅលើអ្វីដែលពួកគេ *ប្រែក្លាយ* ដូចជា « ម៉ាក់ ឬប៉ាសប្បាយចិត្តណាស់ នៅពេលដែលកូនធ្វើការចេញពីដួងចិត្ត » ។

ពេលដែលកូនទទួលសៀវភៅសិក្ខាគារិកពីសាលា យើងអាចសរសើរគេថាគេបាននិទ្ទេសល្អ ប៉ុន្តែវាប្រហែលជាប្រសើរជាង ដើម្បីសរសើរគេ សម្រាប់ភាព*ឧស្សាហ៍ព្យាយាម* របស់គេថា ៖ « កូនបានធ្វើគ្រប់លំហាត់របស់កូន ។ កូនជាម្នាក់ដែលដឹងពីរបៀបដើម្បីតស៊ូ និងបញ្ចប់កិច្ចការដ៏លំបាក — ម៉ាក់ ឬប៉ាមានមោទនភាពចំពោះកូនណាស់ » ។

កំឡុងពេលការសិក្សាព្រះគម្ពីរជាក្រុមគ្រួសារ រកមើល ហើយពិភាក្សាពីគំរូនៃលក្ខណ:ទាំងឡាយដែលអ្នករកឃើញនៅក្នុងការអានរបស់អ្នកថ្ងៃនោះ ។ « ពីព្រោះលក្ខណ:ដូចជាព្រះគ្រីស្ទ គឺជាអំណោយទានមកពីព្រះ ហើយមិនអាចត្រូវបានអភិវឌ្ឍដោយគ្មានជំនួយពីទ្រង់ឡើយ » ( *ប្រកាសដំណឹងល្អយើង* ទំព័រ 117 ) នៅក្នុងការអធិស្ឋានជាគ្រួសារ និងផ្ទាល់ខ្លួន សូមអធិស្ឋានសម្រាប់អំណោយទានទាំងនោះ ។

នៅឯតុអាហារពេលល្ងាច យកឱកាសនិយាយពីលក្ខណៈទាំងឡាយ ជាពិសេស លក្ខណៈទាំងឡាយដែលអ្នកបានរកឃើញនៅក្នុងព្រះគម្ពីរពីព្រឹកមិញ ។ « តើអ្នកបានក្លាយជាមិត្តល្អដោយរបៀបណាថ្ងៃនេះ ? តើដោយរបៀបណាដែលអ្នកក្លាយជាមនុស្សដែលអាចពឹងពាក់បាន ? ស្មោះត្រង់ ? » មានចំណុចនៃលក្ខណៈទាំងឡាយនៅក្នុងព្រះគម្ពីរ ដែលត្រូវបង្រៀន និងរៀន ។

របៀបសំខាន់បំផុតនៅក្នុងការបង្រៀនពី *ការប្រែក្លាយ* គឺត្រូវ *ប្រែក្លាយ* ជាឪពុកម្ដាយ ដូចជាព្រះវរបិតានៅស្ថានសួគ៌របស់យើង ។ ទ្រង់គឺជាឪពុកដ៏ល្អឥតខ្ចោះ ហើយទ្រង់បានចែកចាយជាមួយយើងនូវសៀវភៅហ្វឹកហ្វឺនឪពុកម្ដាយ — គឺជាព្រះគម្ពីរនោះឯង ។

សុន្ទរកថារបស់ខ្ញុំថ្ងៃនេះផ្ដោតសំខាន់ទៅលើឪពុកម្ដាយ ប៉ុន្តែគោលការណ៍ទាំងនេះអនុវត្តចំពោះមនុស្សគ្រប់រូប ។ សូមឲ្យការខិតខំរបស់អ្នកក្នុងការអភិវឌ្ឍលក្ខណៈដូចព្រះគ្រីស្ទបានទទួលជោគជ័យ ដើម្បីឲ្យរូបភាពរបស់ទ្រង់មាននៅលើទឹកមុខរបស់អ្នក និងសូមឲ្យលក្ខណៈរបស់ទ្រង់សម្ដែងចេញតាមការប្រព្រឹត្តរបស់អ្នក ។ បន្ទាប់មក នៅពេលដែលកូនៗរបស់អ្នក ឬអ្នកផ្សេងទៀតទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់ និងមើលឃើញពីការប្រព្រឹត្តអ្នក នោះនឹងនាំពួកគេទៅរកទ្រង់ នេះជាការអធិស្ឋាន និងទីបន្ទាល់របស់ខ្ញុំ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. Carol Dweck, « Make Up Your Mind to Succeed » *Reader's Digest* ខែ ឧសភា ឆ្នាំ 2009 ទំព័រ 54–55 ។